ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១៩-១២-២០១៦ -ព្រះរាជក្រម នស/រកម/១២១៦/០២០ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ

*ត មកពីរាជកិច្ចលេខ ៩៣* ១០៥១៩


### ២~ព្រះរាជក្រឹត្យ


០៩-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៣៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចិន យ៉ាន** (CHEN YAN) ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ចាន់ អ៊ិរិច ង៉ាន** (CHAN ERIC NGAN) ១០៥៤២

០៩-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៣៨ ស្តីពី ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបង្ខិតបង្ខំ ដល់កញ្ញា **ស៊ុន ណាលី** (SUN NALY) ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដែលបច្ចុប្បន្នកំពុងរស់នៅសាធារណរដ្ឋចិន ១០៥៤៣

០៩-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៣៩ ស្តីពី ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបង្ខិតបង្ខំ ដល់អ្នកស្រី **អៀង សេរីយ៉ា** (EANG SEREYA) ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដែលបច្ចុប្បន្នកំពុងរស់នៅសាធារណរដ្ឋកូរ៉េ ១០៥៤៤

០៩-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៤០ ស្តីពី ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបង្ខិតបង្ខំ ដល់អ្នកស្រី **ថាម ណាអេង** (THAM NA ENG) ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដែលបច្ចុប្បន្នកំពុងរស់នៅប្រទេសសិង្ហបុរី ១០៥៤៥

០៩-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៤១ ស្តីពី ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបង្ខិតបង្ខំ ដល់អ្នកស្រី **ម៉ី គីមឆេង** (MEY KIM CHHENG) ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដែលបច្ចុប្បន្នកំពុងរស់នៅសាធារណរដ្ឋចិន ១០៥៤៦

០៩-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៤២ ស្តីពី ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ដោយគ្មានការបង្ខិតបង្ខំ ដល់អ្នកស្រី **ភេន សារ៉ន** (PHEN SARON) ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដែលបច្ចុប្បន្នកំពុងរស់នៅសាធារណរដ្ឋកូរ៉េ ១០៥៤៧

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៤៣ ស្តីពី ការតែងតាំងមន្ត្រីរាជការ ០៤ រូប និង បញ្ចប់ពីទីប្រឹក្សា និងជំនួយការអមក្រសួងបរិស្ថាន ០៤ រូប ១០៥៤៨

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៤៤ ស្តីពី ការតែងតាំងលោក **ហួត សុវណ្ណ** ជា ឧកញ៉ា ១០៥៤៩

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៤៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ដល់លោកឧត្តមសេនីយ៍ទោ **សាយ ម៉េងឃាង** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃ ក្រសួងមហាផ្ទៃ ១០៥៥០

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៤៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយ នគរបាល ថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ១០៥៥១

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៤៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៦ រូប ១០៥៥២

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៤៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តម សេនីយ៍ទោ ដល់លោកឧត្តមសេនីយ៍ត្រី **ឃាង សុវណ្ណជា** នាយនគរបាលថ្នាក់ ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១០៥៥៣

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៤៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តម សេនីយ៍ទោ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃ ក្រសួងមហាផ្ទៃ ចំនួន ០៦ រូប ១០៥៥៤

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៥០ ស្តីពី ការតាំងស៊ប់ដល់មន្ត្រីរាជការ ចំនួន ១៦ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ១០៥៥៥

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៥១ ស្តីពី ការដាក់មន្ត្រីរាជការ ៤៩ រូប របស់ក្រសួង ស្ថាប័ន ចំនួន ១៥ ឱ្យចូលនិវត្តន៍ ១០៥៥៧

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៥២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ១៤ រូប ១០៥៦១

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៥៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ អស់លោក ចំនួន ០៣ រូប ១០៥៦២

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៥៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ៦៦ រូប ១០៥៦៣

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៥៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក និងលោកស្រី ចំនួន ៨៥ រូប ១០៥៦៦

១៥-១២-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/១២១៦/១១៥៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ឧកញ៉ា លោកជំទាវ អស់លោក លោកស្រី ឧបាសក និងឧបាសិកា ចំនួន ៧៥ រូប ១០៥៦៨

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

១៩-១២-២០១៦ -អនុក្រឹត្យលេខ ២៦២ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពី ការទទួលស្គាល់សមាជិកជ្រើសតាំងមណ្ឌលសភាពាណិជ្ជកម្ម ខេត្តសៀមរាប អាណត្តិទី២ លើកទី១ ១០៥៧០

២៦-១២-២០១៦ -អនុក្រឹត្យលេខ ២៦៣ អនក្រ.បក ស្តីពី ការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ១០៥៧៣

២៦-១២-២០១៦ -អនុក្រឹត្យលេខ ២៦៤ អនក្រ.បក ស្តីពី ការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ១០៥៨១

១៩-១២-២០១៦ -អនុក្រឹត្យលេខ ១២៣២ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម មណ្ឌលខេត្តស្វាយរៀង អាណត្តិទី១ លើកទី១ ១០៦០៤

១៩-១២-២០១៦ -អនុក្រឹត្យលេខ ១២៣៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ១០៦០៦

## ២-សេចក្តីសម្រេច

០៦-១២-២០១៦ -សេចក្តីសម្រេចលេខ ១២៥ សសរ ស្តីពី ការកែសម្រួលប្រការ ១ នៃសេចក្តីសម្រេចលេខ ៣៨ សសរ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិ ដើម្បីអនុវត្តផែនការសកម្មភាពស្តីពីយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាយ៉េយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ ១០៦២១

០៦-១២-២០១៦ -សេចក្តីសម្រេចលេខ ១២៦ សសរ ស្តីពី ការបង្កើតគណៈកម្មការតម្រង់ទិស សម្រាប់ការសាងសង់អាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ ១០៦២៣

០៧-១២-២០១៦ -សេចក្តីសម្រេចលេខ ១២៧ សសរ ស្តីពី ការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ១០៦២៦

១៣-១២-២០១៦ -សេចក្តីសម្រេចលេខ ១២៨ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទ នៅបឹងទន្លេសាប ១០៦២៩

# III-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៩-១២-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១៤៣៩ សហវ.ប្រក ស្តីពីការបង្កើតរជ្ជទេយ្យចំណូល នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១០៦៣២

តមកពីរាជកិច្ចលេខ ៩៣

# ព្រះរាជក្រម

នស/រកម/១២១៦/០២០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៥ ស្តីពីការប្រែប្រួលអាកាសធាតុ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក នាថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៦ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកម/១២១៦/០១៩៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**ហត្ថលេខា**
**សាយ សំអាល់**

**លេខៈ ១១៦២ស.ណ**
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊យ សុខា**

ដើម្បីផ្តល់ទិដ្ឋភាពរួមពេញលេញមួយ ទៅតាមកម្រិតអាចធ្វើបាន នៃការគាំទ្រហិរញ្ញវត្ថុសរុបដែលបានផ្តល់ ដើម្បីរាយការណ៍ពីរបាយការណ៍សំយោគជាសកលនៅក្រោមមាត្រា១៤។

៧. ភាគីនីមួយៗត្រូវផ្តល់ជាទៀងទាត់នូវព័ត៌មានខាងក្រោម៖

(ក) របាយការណ៍សារពើភ័ណ្ឌជាតិអំពីការបញ្ចេញឧស្ម័នដោយសកម្មភាពមនុស្សគិតតាមប្រភពបញ្ចេញនិងការស្រូបឧស្ម័នដោយអាងស្រូបឧស្ម័នផ្ទះកញ្ចក់ ដែលរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្រអនុវត្តន៍ល្អ ដែលទទួលយកដោយក្រុមការងារអន្តររដ្ឋាភិបាលប្រែប្រួលអាកាសធាតុនិងឯកភាពពីសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

(ខ) ព័ត៌មានចាំបាច់ដើម្បីតាមដានវឌ្ឍនភាពដែលសម្រេចបាននៅក្នុងការអនុវត្ត និងលទ្ធផលក្នុងការរួមចំណែកប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ នៅក្រោមមាត្រា៤។

៨. ភាគីនីមួយៗក៏គួរផ្តល់ព័ត៌មានទាក់ទងនឹងបន្សាំនិងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្រោមមាត្រា៧ទៅតាមករណីសមស្រប។

៩. បណ្តាភាគីប្រទេសអភិវឌ្ឍន៍ត្រូវ ហើយបណ្តាភាគីដទៃទៀតដែលផ្តល់ការគាំទ្រក៏គួរ ផ្តល់ព័ត៌មានអំពីការគាំទ្រផ្នែកហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាព ដែលបានផ្តល់ឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍នៅក្រោមមាត្រា៩, ១០ និង ១១។

១០. បណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍គួរផ្តល់ព័ត៌មានអំពីតម្រូវការ និងការទទួលបាននូវការគាំទ្រផ្នែកហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាពនៅក្រោមមាត្រា៩, ១០ និង ១១។

១១. ព័ត៌មានដែលភាគីនីមួយៗបានដាក់ជូននៅក្រោមកថាខណ្ឌ៧និង៩ នៃមាត្រានេះ ត្រូវពិនិត្យដោយអ្នកជំនាញការបច្ចេកទេសអនុលោមតាមសេចក្តីសម្រេច 1/CP.21។ ចំពោះបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ដែលត្រូវការព័ត៌មាននេះ ដោយគិតពិចារណាពីសមត្ថភាពរបស់ខ្លួន ដំណើរការពិនិត្យត្រូវរួមបញ្ចូលជំនួយក្នុងការកំណត់តម្រូវការកសាងសមត្ថភាព។ លើសពីនេះ ភាគីនីមួយៗ ត្រូវចូលរួមការអនុវត្តនិងការសម្រេចបានលើការចូលរួមចំណែកប្តេជ្ញាអនុវត្តថ្នាក់ជាតិរៀងៗខ្លួន តាមបែបសម្របសម្រួល និងការគិតគូរបែបលក្ខណៈពហុភាគីអំពីវឌ្ឍនភាពដោយគោរពតាមកិច្ចខិតខំប្រឹងប្រែងនៅក្រោមមាត្រា៩។

១២. ការពិនិត្យរបស់អ្នកជំនាញបច្ចេកទេសនៅក្រោមកថាខណ្ឌនេះ ត្រូវរួមមានការពិចារណារបស់ភាគីដែលមានការគាំទ្រទៅតាមករណីពាក់ព័ន្ធនិងការអនុវត្តព្រមទាំងការសម្រេចបានលើការចូលរួមចំណែកប្តេជ្ញាអនុវត្តថ្នាក់ជាតិរបស់ភាគីនោះ។ ការពិនិត្យ ក៏ត្រូវកំណត់ពីវិស័យនានាសម្រាប់កែលម្អរបស់ភាគី និងរួមបញ្ចូលទាំងការពិនិត្យលើសង្គតិភាពនៃព័ត៌មានជាមួយបែបបទ នីតិវិធី និងគោលការណ៍ណែនាំ ដូចមានយោងនៅក្នុងកថាខណ្ឌ១៣ នៃមាត្រានេះ ដោយគិតគូរអំពីភាពបត់បែនដែលបានព្រមព្រៀងឱ្យទៅភាគីនៅក្រោមកថាខណ្ឌ២នៃមាត្រានេះ។ ការពិនិត្យនេះត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសលើសមត្ថភាពនិងកាលៈទេសៈរបស់ជាតិនៃបណ្តាភាគី ប្រទេសកំពុងអភិវឌ្ឍន៍។

១៣. នាសម័យប្រជុំលើកទីមួយរបស់ខ្លួន ដោយបន្ថែមលើបទពិសោធន៍ចេញពីការចាត់ចែងដែលទាក់ទងនឹងតម្លាភាព នៅក្រោមអនុសញ្ញានេះ និងពន្យល់ពិស្តារអំពីប្រការនានានៅក្រោមមាត្រានេះ សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះត្រូវអនុម័តបែបបទ នីតិវិធី និងគោលការណ៍ណែនាំរួម ទៅតាមករណីសមស្រប សម្រាប់តម្លាភាពនៃសកម្មភាព និងការគាំទ្រ។

១៤. ការគាំទ្រត្រូវផ្តល់ទៅឱ្យបណ្តាប្រទេសកំពុងអភិវឌ្ឍន៍សម្រាប់ការអនុវត្តមាត្រានេះ។

១៥. ការគាំទ្រត្រូវផ្តល់ជាបន្តបន្ទាប់ទៅឱ្យបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ការកសាងសមត្ថភាពដែលទាក់ទងនឹងតម្លាភាព។

## មាត្រា១៤

១. សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើរបាយការណ៍សំយោគទៀងទាត់អំពីការអនុវត្តកិច្ចព្រមព្រៀងនេះ ដើម្បីវាយតម្លៃវឌ្ឍនភាពរួមគ្នា ក្នុងការឈានទៅសម្រេចបំណងនៃកិច្ចព្រមព្រៀងនេះ និងគោលបំណងរយៈពេលវែង (ដែលហៅថា "របាយការណ៍សំយោគជាសកល")។ សន្និសីទត្រូវរៀបចំឱ្យបានទូលំទូលាយ និងតាមរបៀបសម្របសម្រួលផងដែរដោយពិចារណាអំពីការកាត់បន្ថយ បន្សាំ និងមធ្យោបាយនៃការអនុវត្ត និងគាំទ្រ ហើយក្នុងបរិបទសមធម៌ និងវិទ្យាសាស្ត្រសមស្របបំផុតដែលមាន។

២. សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវរៀបចំរបាយការណ៍សំយោគជាសកលលើក

ទី១របស់ខ្លួននៅឆ្នាំ២០២៣ និងបន្ទាប់ពីនោះ រៀងរាល់ប្រាំឆ្នាំម្តង លើកលែងតែមានការសម្រេចផ្ទុយពីនេះដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៣. លទ្ធផលនៃរបាយការណ៍សរុបជាសកល ត្រូវជូនដំណឹងដល់បណ្តាភាគីក្នុងការធ្វើបច្ចុប្បន្នកម្ម និងការពង្រឹងសកម្មភាពនិងការគាំទ្ររបស់ខ្លួនតាមបែបការប្តេជ្ញាអនុវត្តនៅថ្នាក់ជាតិ ស្របតាមប្រការនានានៃកិច្ចព្រមព្រៀងនេះ ក៏ដូចជាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់សកម្មភាពអាកាសធាតុ ។

## មាត្រា១៥

១. យន្តការមួយដើម្បីសម្រួលឱ្យមានការអនុវត្ត និងលើកកម្ពស់អនុលោមភាពតាមប្រការនានានៃកិច្ចព្រមព្រៀងនេះ ត្រូវបានបង្កើតឡើងចាប់ពីនេះទៅ។

២. យន្តការដូចមានយោងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ត្រូវមានគណៈកម្មការមួយដែលមានមុខងារ និងចរិតលក្ខណៈជាអ្នកជំនាញ និងជួយសម្រួលយន្តការនេះ ប្រកបដោយតម្លាភាព មិនវាយប្រហារនិងមិនដាក់ទណ្ឌកម្មទៅភាគីណាមួយឡើយ។ គណៈកម្មការនេះត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសលើកាលៈទេសៈនិងសមត្ថភាពជាតិ របស់បណ្តាភាគី។

៣. គណៈកម្មការនេះត្រូវប្រតិបត្តិការទៅតាមបែបបទ និងនីតិវិធីដែលអនុម័តដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ នាសម័យប្រជុំលើកទី១របស់ខ្លួន និងរាយការណ៍ប្រចាំឆ្នាំទៅសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

## មាត្រា១៦

១. សន្និសីទបណ្តាភាគីដែលជាអង្គកំពូលនៃអនុសញ្ញានេះ ត្រូវមាននាទីជាកិច្ចប្រជុំបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ។

២. បណ្តាភាគីក្នុងអនុសញ្ញា ដែលមិនមែនជាភាគីក្នុងកិច្ចព្រមព្រៀងនេះ អាចចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងដំណើរការប្រព្រឹត្តទៅនៃសម័យប្រជុំនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។ នៅពេលសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ការសម្រេចនានាដែលនៅក្រោមកិច្ចព្រមព្រៀង ត្រូវធ្វើឡើងដោយបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះតែប៉ុណ្ណោះ។

៣. នៅពេលសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ សមាជិកណាមួយនៃការិយាល័យសន្និសីទបណ្តាភាគី ដែលតំណាងឱ្យភាគីមួយនៅក្នុងអនុសញ្ញានេះ ប៉ុន្តែពេលនោះមិនមែនជាភាគីមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវជំនួសដោយសមាជិកបន្ថែមដែលត្រូវបានបោះឆ្នោតដោយ និងចេញពីក្នុងចំណោមបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ។

៤. សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើការពិនិត្យជាទៀងទាត់នូវការអនុវត្តកិច្ចព្រមព្រៀងនេះ និងត្រូវធ្វើសេចក្តីសម្រេចចាំបាច់នៅក្នុងអាណត្តិរបស់ខ្លួនដើម្បីជំរុញការអនុវត្តកិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាព។ សន្និសីទបណ្តាភាគីនេះត្រូវបំពេញមុខងារដែលកំណត់ដោយកិច្ចព្រមព្រៀងនេះ និងត្រូវ៖

(ក) បង្កើតអង្គចំណុះតាមការចាំបាច់សម្រាប់អនុវត្តកិច្ចព្រមព្រៀងនេះ និង

(ខ) អនុវត្តមុខងារដទៃទៀតតាមលក្ខខណ្ឌតម្រូវសម្រាប់អនុវត្តកិច្ចព្រមព្រៀងនេះ។

៥. វិធាននៃនីតិវិធីនៅក្នុងសន្និសីទបណ្តាភាគី និងនៅក្នុងនីតិវិធីហិរញ្ញវត្ថុ ដែលបានអនុវត្តនៅក្រោមអនុសញ្ញានេះ ក៏ត្រូវយកមកអនុវត្តនៅក្រោមកិច្ចព្រមព្រៀងនេះផងដែរ ដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់ លើកលែងតែមានការសម្រេចជាឯកឆន្ទផ្សេងទៀតដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៦. សម័យប្រជុំលើកទីមួយនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវបានកោះប្រជុំដោយលេខាធិការដ្ឋាន ដោយភ្ជាប់ជាមួយសម័យប្រជុំលើកទីមួយនៃសន្និសីទបណ្តាភាគីដែលគ្រោងធ្វើឡើងនៅក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ សម័យប្រជុំសាមញ្ញជាបន្តបន្ទាប់នៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវធ្វើឡើងព្រមពេលជាមួយគ្នានឹងសម័យប្រជុំសាមញ្ញនៃសន្និសីទបណ្តាភាគី លើកលែងតែមានការសម្រេចផ្ទុយពីនេះដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

៧. សម័យប្រជុំវិសាមញ្ញនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងនៅក្នុងពេលណា

មួយផ្សេង តាមការចាំបាច់ដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ឬ តាមការស្នើសុំជាលាយលក្ខណ៍អក្សរដោយភាគីណាមួយ នៅក្នុងករណីដែលមានការគាំទ្រយ៉ាងតិចមួយភាគបីនៃចំនួនភាគីទាំងអស់ នៅក្នុងកំលុងពេលប្រាំមួយខែក្រោយការជូនដំណឹងដោយលេខាធិការដ្ឋានអំពីការស្នើសុំនេះ។

៨. អង្គការសហប្រជាជាតិ និងទីភ្នាក់ងារឯកទេសរបស់ខ្លួន និងទីភ្នាក់ងាថាមពលអាតូមិកអន្តរជាតិ ក៏ដូចជា រដ្ឋសមាជិកណាមួយនៃអង្គការឬទីភ្នាក់ងារ ឬអ្នកសង្កេតការណ៍ ដែលមិនមែនជាភាគីនៅក្នុងអនុសញ្ញានេះ អាចមានតំណាងនៅក្នុងសម័យប្រជុំនានានៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ក្នុងនាមជាអ្នកសង្កេតការណ៍។ អង្គភាព ឬទីភ្នាក់ងារណាមួយ ទោះជាថ្នាក់ជាតិ ឬអន្តរជាតិ រដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ដែលមានសមត្ថភាពលើកិច្ចការដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ ហើយដែលបានជូនដំណឹងមកលេខាធិការដ្ឋានអំពីបំណងក្នុងការបញ្ជូនតំណាងរបស់ខ្លួនចូលរួមក្នុងសម័យប្រជុំណាមួយនៃសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ក្នុងនាមជាអ្នកសង្កេតការណ៍ អាចបានទទួលការអនុញ្ញាតឱ្យបញ្ជូនតំណាងដើម្បីចូលរួម លុះត្រាតែមានការជំទាស់យ៉ាងតិចមួយភាគបីនៃចំនួនភាគីទាំងអស់ក្នុងកិច្ចព្រមព្រៀងនេះ។ ការអនុញ្ញាត និងការចូលរួមរបស់អ្នកសង្កេតការណ៍ ត្រូវធ្វើឡើងតាមវិធាននៃនីតិវិធីដូចមានយោងក្នុងកថាខណ្ឌ៥ នៃមាត្រានេះ។

## មាត្រា១៧

១. លេខាធិការដ្ឋានដែលបង្កើតឡើងតាមមាត្រា៨ នៃអនុសញ្ញានេះ ត្រូវដើរតួជាលេខាធិការដ្ឋាននៃកិច្ចព្រមព្រៀងនេះ។

២. មាត្រា៨ កថាខណ្ឌ២ នៃអនុសញ្ញានេះ អំពីមុខងាររបស់លេខាធិការដ្ឋាន ហើយមាត្រា៨ កថាខណ្ឌ៣ នៃអនុសញ្ញានេះ អំពីការរៀបចំចាត់ចែងសម្រាប់មុខងាររបស់លេខាធិការដ្ឋាន ត្រូវយកមកអនុវត្ត ដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់នៅក្នុងកិច្ចព្រមព្រៀងនេះ។ លើសពីនេះ លេខាធិការដ្ឋាននេះត្រូវអនុវត្តមុខងារនានាដែលបានកំណត់នៅក្រោមកិច្ចព្រមព្រៀងនេះ និងដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។

## មាត្រា១៨

១. អង្គចំណុះសម្រាប់ប្រឹក្សាយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះសម្រាប់អនុវត្តន៍ ដែលបានបង្កើតឡើងតាមមាត្រា៩ និង១០នៃអនុសញ្ញាត្រូវមាននាទីជាអង្គចំណុះសម្រាប់ប្រឹក្សាយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះសម្រាប់អនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ។ ប្រការនានានៃអនុសញ្ញានេះ ដែលទាក់ទងនឹងមុខងាររបស់អង្គចំណុះទាំងពីរនេះ ត្រូវតែយកមកអនុវត្តសម្រាប់កិច្ចព្រមព្រៀងនេះ ដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់។ សម័យប្រជុំនៃអង្គចំណុះសម្រាប់ប្រឹក្សាយោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះសម្រាប់អនុវត្តន៍កិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងជាមួយគ្នានឹងកិច្ចប្រជុំនៃអង្គចំណុះសម្រាប់ផ្តល់យោបល់ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអង្គចំណុះសម្រាប់អនុវត្តន៍នៃអនុសញ្ញានេះ។

២. បណ្តាភាគីក្នុងអនុសញ្ញាដែលមិនមែនជាបណ្តាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ អាចចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងដំណើរការប្រព្រឹត្តទៅនៃសម័យប្រជុំណាមួយរបស់អង្គចំណុះ។ នៅពេលដែលអង្គចំណុះទាំងនេះ ដើរតួជាអង្គចំណុះនៃកិច្ចព្រមព្រៀងនេះ សេចក្តីសម្រេចនានានៅក្រោមកិច្ចព្រមព្រៀងនេះ នឹងត្រូវធ្វើឡើងដោយបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះតែប៉ុណ្ណោះ។

៣. នៅពេលដែលអង្គចំណុះនានាដែលបានបង្កើតឡើងតាមមាត្រា៩ និង១០ នៃអនុសញ្ញានេះ អនុវត្តមុខងាររបស់ខ្លួនទាក់ទងជាមួយកិច្ចការនានាពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ សមាជិកណាមួយក្នុងការិយាល័យរបស់អង្គចំណុះដែលតំណាងឱ្យភាគីណាមួយនៅក្នុងអនុសញ្ញានេះ ប៉ុន្តែនៅពេលនោះពុំមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ ត្រូវតែជំនួសដោយសមាជិកបន្ថែមដែលនឹងត្រូវជ្រើសរើសដោយនិងក្នុងចំណោមបណ្តាភាគីនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា១៩

១. អង្គចំណុះ ឬការចាត់ចែងស្ថាប័នដទៃទៀត បានបង្កើតឡើងដោយឬនៅក្រោមអនុសញ្ញានេះ ក្រៅពីនោះត្រូវយោងទៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបម្រើនាទីក្នុងកិច្ចព្រមព្រៀងនេះ ទៅតាមសេចក្តីសម្រេចដោយសន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ។ សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវគូសបញ្ជាក់ពីមុខងារនានា

ដែលត្រូវអនុវត្តដោយអង្គចំណុះឬការចាត់ចែងបែបនេះ។

២. សន្និសីទបណ្តាភាគីមាននាទីជាកិច្ចប្រជុំបណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ អាចផ្តល់សេចក្តីណែនាំបន្ថែមដល់អង្គចំណុះនិងការចាត់ចែងបែបនេះ។

## មាត្រា២០

១. កិច្ចព្រមព្រៀងនេះនឹងត្រូវបើកចំហសម្រាប់ការចុះហត្ថលេខា និងផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តដោយរដ្ឋនានា និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលជាភាគីក្នុងអនុសញ្ញានេះ។ កិច្ចព្រមព្រៀងនេះនឹងត្រូវបើកចំហសម្រាប់ការចុះហត្ថលេខានៅស្នាក់ការកណ្តាលនៃអង្គការសហប្រជាជាតិនាទីក្រុងញ៉ូវយ៉ក ចាប់ពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ដល់ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧។ ចាប់ពីពេលនោះតទៅ កិច្ចព្រមព្រៀងនេះនឹងត្រូវបើកចំហសម្រាប់ការសុំចូលរួមជាភាគី គិតចាប់ពីកាលបរិច្ឆេទ ដែលបិទបញ្ចប់សម្រាប់ការចុះហត្ថលេខា។ លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬការសុំចូលរួមជាភាគី នឹងត្រូវរក្សាទុកនៅក្នុងកន្លែងតំកល់ឯកសារ។

២. អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ណាមួយដែលក្លាយជាភាគីមួយក្នុងកិច្ចព្រមព្រៀងនេះ ដោយគ្មានរដ្ឋសមាជិកណាមួយរបស់ខ្លួនជាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវតែមានភារៈកិច្ចអនុវត្តគ្រប់កាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងនេះ។ នៅក្នុងករណីដែលអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលមានរដ្ឋជាសមាជិកមួយឬច្រើន ដែលជាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ អង្គការនោះនិងរដ្ឋសមាជិករបស់ខ្លួន ត្រូវធ្វើសេចក្តីសម្រេចអំពីការទទួលខុសត្រូវរៀងៗខ្លួនសម្រាប់ការបំពេលកាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងនេះ។ នៅក្នុងករណីបែបនេះ អង្គការនោះនិងរដ្ឋជាសមាជិករបស់ខ្លួន មិនត្រូវទទួលបានសិទ្ធិអនុវត្តន៍នានានៅក្រោមកិច្ចព្រមព្រៀងនេះ នៅក្នុងពេលទន្ទឹមគ្នា។

៣. នៅក្នុងលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬការចូលរួមជាភាគី អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ត្រូវប្រកាសវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ដែលទាក់ទងនឹងកិច្ចការនានាមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។ អង្គការទាំងនេះត្រូវជូនដំណឹងដល់កន្លែងតំកល់ឯកសារ ដែលត្រូវជូនដំណឹងជាបន្តទៅភាគីនានា អំពីការកែប្រែជាទ្រង់ទ្រាយធំណាមួយ ចំពោះវិសាលភាពនៃសមត្ថកិច្ចរបស់ពួកគេ។

## មាត្រា ២១

១. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅក្នុងរយៈពេលសាមសិបថ្ងៃក្រោយកាលបរិច្ឆេទ ដែលយ៉ាងតិចមានភាគីចំនួន៥៥ នៃអនុសញ្ញានេះ ដែលគិតជាបរិមាណសរុប យ៉ាងតិចប្រមាណ៥៥ ភាគរយនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបលើពិភពលោក បានដាក់តំកល់លិខិតូបករណ៍របស់ខ្លួននៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការចូលរួមជាភាគី។

២. សម្រាប់គោលបំណងដែលបានកំណត់តែមួយគត់ដូចក្នុងកថាខណ្ឌ១ នៃមាត្រានេះ "ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបលើពិភពលោក" មានន័យថាជាបរិមាណឧស្ម័នថ្មីបំផុតដែលមាននៅក្នុងរបាយការណ៍ ឬមុនកាលបរិច្ឆេទនៃការអនុម័តកិច្ចព្រមព្រៀងនេះដោយបណ្តាភាគីក្នុងអនុសញ្ញានេះ។

៣. សម្រាប់រដ្ឋនីមួយៗ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលផ្តល់សច្ចាប័ន ទទួលយក ឬអនុម័តកិច្ចព្រមព្រៀងនេះ ឬចូលរួមជាភាគីបន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះកិច្ចព្រមព្រៀងនេះនឹងចូលជាធរមាន នៅក្នុងរយៈពេលសាមសិបថ្ងៃក្រោយកាលបរិច្ឆេទនៃការដាក់តំកល់លិខិតូបករណ៍របស់ខ្លួននៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការចូលរួមជាភាគី ដោយរដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់។

៤. សម្រាប់បំណងនៃកថាខណ្ឌ១ នៃមាត្រានេះ លិខិតូបករណ៍ណាមួយដែលបានតំកល់ទុកដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ មិនត្រូវបានរាប់បញ្ចូលបន្ថែមទៅលើលិខិតូបករណ៍ដែលបានតំកល់ដោយរដ្ឋជាសមាជិករបស់ខ្លួនឡើយ។

## មាត្រា២២

ប្រការនានាក្នុងមាត្រា១៥ នៃអនុសញ្ញាស្តីពីការអនុម័តលើវិសោធនកម្មអនុសញ្ញានេះ ត្រូវយកមកអនុវត្តដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់ចំពោះកិច្ចព្រមព្រៀងនេះ។

### មាត្រា២៣

១. ប្រការនានាក្នុងមាត្រា១៦ នៃអនុសញ្ញាស្តីពីការអនុម័ត និងវិសោធនកម្មឧបសម្ព័ន្ធនានានៃអនុសញ្ញានេះ ត្រូវយកមកអនុវត្ត ដោយមានការកែសម្រួលខ្លះៗតាមការចាំបាច់ចំពោះកិច្ចព្រមព្រៀងនេះ ។

២. ឧបសម្ព័ន្ធនានានៃកិច្ចព្រមព្រៀងនេះ ត្រូវតែជាទម្រង់ផ្នែកសំខាន់មួយ និងលើកលែងតែមានការចែងផ្ទុយពីនេះ សេចក្តីយោងនៃកិច្ចព្រមព្រៀងនេះក៏ជាសេចក្តីយោងទៅនឹងឧបសម្ព័ន្ធណាមួយផងដែរ។ ឧបសម្ព័ន្ធបែបនេះត្រូវរៀបចំជាបញ្ជី ជាទម្រង់ឯកសារ និងសម្ភារៈដទៃទៀតដែលមានលក្ខណៈពិពណ៌នាតាមបែប វិទ្យាសាស្ត្រ បច្ចេកទេស នីតិវិធី ឬរដ្ឋបាល។

### មាត្រា២៤

ប្រការនានាក្នុងមាត្រា១៤ នៃអនុសញ្ញាស្តីពីការដោះស្រាយទំនាស់ ត្រូវយកមកអនុវត្តដោយមានការកែសម្រួលតាមការចាំបាច់ចំពោះកិច្ចព្រមព្រៀងនេះ។

### មាត្រា២៥

១. ភាគីនីមួយៗត្រូវមានសម្លេងមួយនៅក្នុងការបោះឆ្នោត លើកលែងតែករណីដូចមានចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ។

២. នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ត្រូវអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីបោះឆ្នោតដោយមានសម្លេងឆ្នោតស្មើទៅនឹងចំនួនបណ្តារដ្ឋជាសមាជិកជាភាគីក្នុងកិច្ចព្រមព្រៀងនេះ។ អង្គការ នោះមិនត្រូវអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតឡើយ ផ្ទុយមកវិញ ប្រសិនបើរដ្ឋជាសមាជិករបស់ខ្លួនអនុវត្តសិទ្ធិ ក្នុងការបោះឆ្នោត។

### មាត្រា២៦

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវតែជាអ្នកតំកល់ទុកកិច្ចព្រមព្រៀងនេះ។

### មាត្រា២៧

គ្មានសេចក្តីបម្រុងណាមួយអាចត្រូវបានធ្វើឡើងសម្រាប់កិច្ចព្រមព្រៀងនេះ។

### មាត្រា២៨

១. ក្រោយរយៈពេលបីឆ្នាំក្នុងពេលណាមួយគិតចាប់ពីកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះបានចូលជាធរមានសម្រាប់ភាគីមួយ ភាគីនោះអាចដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកកន្លែងតំកល់ឯកសារ។

២. រាល់ការដកខ្លួនណាមួយ ត្រូវមានប្រសិទ្ធភាពក្នុងរយៈពេលមួយឆ្នាំនៃការផុតកំណត់ដោយគិតចាប់ពីកាលបរិច្ឆេទ ដែលកន្លែងតំកល់ឯកសារបានទទួលសេចក្តីជូនដំណឹងអំពីការដកខ្លួនចេញនេះ ឬនៅកាលបរិច្ឆេទណាមួយក្រោយមក តាមការបញ្ជាក់ក្នុងសេចក្តីជូនដំណឹងអំពីការដកខ្លួនចេញនោះ។

៣. បណ្តាភាគីណាមួយដែលដកខ្លួនចេញពីអនុសញ្ញានេះ ត្រូវបានចាត់ទុកថាបានដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះផងដែរ។

### មាត្រា២៩

ច្បាប់ដើមនៃកិច្ចព្រមព្រៀងនេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃប្រើប្រាស់ត្រឹមត្រូវដូចគ្នា ត្រូវដាក់តំកល់ទុកដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។

ធ្វើនៅក្រុងប៉ារីស ថ្ងៃទីដប់ពីរ ខែធ្នូ ឆ្នាំពីរពាន់ដប់ប្រាំ។
ដើម្បីជាសាក្សី អ្នកទទួលសិទ្ធិប្រទាន ដើម្បីចុះហត្ថលេខា បានចុះហត្ថលេខាដើម្បីផ្តល់សុពលភាពលើកិច្ចព្រមព្រៀងនេះ។

---

10. Developing country Parties should provide information on financial, technology transfer and capacity-building support needed and received under Articles 9, 10 and 11.

11. Information submitted by each Party under paragraphs 7 and 9 of this Article shall undergo a technical expert review, in accordance with decision 1/CP.21. For those developing country Parties that need it in the light of their capacities, the review process shall include assistance in identifying capacity-building needs. In addition, each Party shall participate in a facilitative, multilateral consideration of progress with respect to efforts under Article 9, and its respective implementation and achievement of its nationally determined contribution.

12. The technical expert review under this paragraph shall consist of a consideration of the Party's support provided, as relevant, and its implementation and achievement of its nationally determined contribution. The review shall also identify areas of improvement for the Party, and include a review of the consistency of the information with the modalities, procedures and guidelines referred to in paragraph 13 of this Article, taking into account the flexibility accorded to the Party under paragraph 2 of this Article. The review shall pay particular attention to the respective national capabilities and circumstances of developing country Parties.

13. The Conference of the Parties serving as the meeting of the Parties to this Agreement shall, at its first session, building on experience from the arrangements related to transparency under the Convention, and elaborating on the provisions in this Article, adopt common modalities, procedures and guidelines, as appropriate, for the transparency of action and support.

14. Support shall be provided to developing countries for the implementation of this Article.

15. Support shall also be provided for the building of transparency-related capacity of developing country Parties on a continuous basis.

## Article 14

1. The Conference of the Parties serving as the meeting of the Parties to this Agreement shall periodically take stock of the implementation of this Agreement to assess the collective progress towards achieving the purpose of this Agreement and its long-term goals (referred to as the "global stocktake"). It shall do so in a comprehensive and facilitative manner, considering mitigation, adaptation and the

means of implementation and support, and in the light of equity and the best available science.

2. The Conference of the Parties serving as the meeting of the Parties to this Agreement shall undertake its first global stocktake in 2023 and every five years thereafter unless otherwise decided by the Conference of the Parties serving as the meeting of the Parties to this Agreement.

3. The outcome of the global stocktake shall inform Parties in updating and enhancing, in a nationally determined manner, their actions and support in accordance with the relevant provisions of this Agreement, as well as in enhancing international cooperation for climate action.

**Article 15**

1. A mechanism to facilitate implementation of and promote compliance with the provisions of this Agreement is hereby established.

2. The mechanism referred to in paragraph 1 of this Article shall consist of a committee that shall be expert-based and facilitative in nature and function in a manner that is transparent, non-adversarial and non-punitive. The committee shall pay particular attention to the respective national capabilities and circumstances of Parties.

3. The committee shall operate under the modalities and procedures adopted by the Conference of the Parties serving as the meeting of the Parties to this Agreement at its first session and report annually to the Conference of the Parties serving as the meeting of the Parties to this Agreement.

**Article 16**

1. The Conference of the Parties, the supreme body of the Convention, shall serve as the meeting of the Parties to this Agreement.

2. Parties to the Convention that are not Parties to this Agreement may participate as observers in the proceedings of any session of the Conference of the Parties serving as the meeting of the Parties to this Agreement. When the Conference of the Parties serves as the meeting of the Parties to this Agreement, decisions under this Agreement shall be taken only by those that are Parties to this Agreement.

3. When the Conference of the Parties serves as the meeting of the Parties to this Agreement, any member of the Bureau of the Conference of the Parties representing a Party to the Convention but, at that time, not a Party to this Agreement, shall be replaced by an additional member to be elected by and from amongst the Parties to this Agreement.

4. The Conference of the Parties serving as the meeting of the Parties to this Agreement shall keep under regular review the implementation of this Agreement and shall make, within its mandate, the decisions necessary to promote its effective implementation. It shall perform the functions assigned to it by this Agreement and shall:

(a) Establish such subsidiary bodies as deemed necessary for the implementation of this Agreement; and

(b) Exercise such other functions as may be required for the implementation of this Agreement.

5. The rules of procedure of the Conference of the Parties and the financial procedures applied under the Convention shall be applied *mutatis mutandis* under this Agreement, except as may be otherwise decided by consensus by the Conference of the Parties serving as the meeting of the Parties to this Agreement.

6. The first session of the Conference of the Parties serving as the meeting of the Parties to this Agreement shall be convened by the secretariat in conjunction with the first session of the Conference of the Parties that is scheduled after the date of entry into force of this Agreement. Subsequent ordinary sessions of the Conference of the Parties serving as the meeting of the Parties to this Agreement shall be held in conjunction with ordinary sessions of the Conference of the Parties, unless otherwise decided by the Conference of the Parties serving as the meeting of the Parties to this Agreement.

7. Extraordinary sessions of the Conference of the Parties serving as the meeting of the Parties to this Agreement shall be held at such other times as may be deemed necessary by the Conference of the Parties serving as the meeting of the Parties to this Agreement or at the written request of any Party, provided that, within six months of the request being communicated to the Parties by the secretariat, it is supported by at least one third of the Parties.

8. The United Nations and its specialized agencies and the International Atomic Energy Agency, as well as any State member thereof or observers thereto not party to the Convention, may be represented at sessions of the Conference of the Parties serving as the meeting of the Parties to this Agreement as observers. Any body or agency, whether national or international, governmental or non-governmental, which is qualified in matters covered by this Agreement and which has informed the secretariat of its wish to be represented at a session of the Conference of the Parties serving as the meeting of the Parties to this Agreement as an observer, may be so admitted unless at least one third of the Parties present object. The admission and participation of observers shall be subject to the rules of procedure referred to in paragraph 5 of this Article.

## Article 17

1. The secretariat established by Article 8 of the Convention shall serve as the secretariat of this Agreement.

2. Article 8, paragraph 2, of the Convention on the functions of the secretariat, and Article 8, paragraph 3, of the Convention, on the arrangements made for the functioning of the secretariat, shall apply *mutatis mutandis* to this Agreement. The secretariat shall, in addition, exercise the functions assigned to it under this Agreement and by the Conference of the Parties serving as the meeting of the Parties to this Agreement.

## Article 18

1. The Subsidiary Body for Scientific and Technological Advice and the Subsidiary Body for Implementation established by Articles 9 and 10 of the Convention shall serve, respectively, as the Subsidiary Body for Scientific and Technological Advice and the Subsidiary Body for Implementation of this Agreement. The provisions of the Convention relating to the functioning of these two bodies shall apply *mutatis mutandis* to this Agreement. Sessions of the meetings of the Subsidiary Body for Scientific and Technological Advice and the Subsidiary Body for Implementation of this Agreement shall be held in conjunction with the meetings of, respectively, the Subsidiary Body for Scientific and Technological Advice and the Subsidiary Body for Implementation of the Convention.

2. Parties to the Convention that are not Parties to this Agreement may participate as observers in the proceedings of any session of the subsidiary bodies. When the subsidiary bodies serve as the subsidiary bodies of this Agreement, decisions under this Agreement shall be taken only by those that are Parties to this Agreement.

3. When the subsidiary bodies established by Articles 9 and 10 of the Convention exercise their functions with regard to matters concerning this Agreement, any member of the bureaux of those subsidiary bodies representing a Party to the Convention but, at that time, not a Party to this Agreement, shall be replaced by an additional member to be elected by and from amongst the Parties to this Agreement.

## Article 19

1. Subsidiary bodies or other institutional arrangements established by or under the Convention, other than those referred to in this Agreement, shall serve this Agreement upon a decision of the Conference of the Parties serving as the meeting of the Parties to this Agreement. The Conference of the Parties serving as the meeting of the Parties to this Agreement shall specify the functions to be exercised by such subsidiary bodies or arrangements.

2. The Conference of the Parties serving as the meeting of the Parties to this Agreement may provide further guidance to such subsidiary bodies and institutional arrangements.

## Article 20

1. This Agreement shall be open for signature and subject to ratification, acceptance or approval by States and regional economic integration organizations that are Parties to the Convention. It shall be open for signature at the United Nations Headquarters in New York from 22 April 2016 to 21 April 2017. Thereafter, this Agreement shall be open for accession from the day following the date on which it is closed for signature. Instruments of ratification, acceptance, approval or accession shall be deposited with the Depositary.

2. Any regional economic integration organization that becomes a Party to this Agreement without any of its member States being a Party shall be bound by all the obligations under this Agreement. In the case of regional economic integration organizations with one or more member States that are Parties to this Agreement,

the organization and its member States shall decide on their respective responsibilities for the performance of their obligations under this Agreement. In such cases, the organization and the member States shall not be entitled to exercise rights under this Agreement concurrently.

3. In their instruments of ratification, acceptance, approval or accession, regional economic integration organizations shall declare the extent of their competence with respect to the matters governed by this Agreement. These organizations shall also inform the Depositary, who shall in turn inform the Parties, of any substantial modification in the extent of their competence.

**Article 21**

1. This Agreement shall enter into force on the thirtieth day after the date on which at least 55 Parties to the Convention accounting in total for at least an estimated 55 per cent of the total global greenhouse gas emissions have deposited their instruments of ratification, acceptance, approval or accession.

2. Solely for the limited purpose of paragraph 1 of this Article, "total global greenhouse gas emissions" means the most up-to-date amount communicated on or before the date of adoption of this Agreement by the Parties to the Convention.

3. For each State or regional economic integration organization that ratifies, accepts or approves this Agreement or accedes thereto after the conditions set out in paragraph 1 of this Article for entry into force have been fulfilled, this Agreement shall enter into force on the thirtieth day after the date of deposit by such State or regional economic integration organization of its instrument of ratification, acceptance, approval or accession.

4. For the purposes of paragraph 1 of this Article, any instrument deposited by a regional economic integration organization shall not be counted as additional to those deposited by its member States.

**Article 22**

The provisions of Article 15 of the Convention on the adoption of amendments to the Convention shall apply *mutatis mutandis* to this Agreement.

**Article 23**

1. The provisions of Article 16 of the Convention on the adoption and amendment of annexes to the Convention shall apply *mutatis mutandis* to this Agreement.

2. Annexes to this Agreement shall form an integral part thereof and, unless otherwise expressly provided for, a reference to this Agreement constitutes at the same time a reference to any annexes thereto. Such annexes shall be restricted to lists, forms and any other material of a descriptive nature that is of a scientific, technical, procedural or administrative character.

**Article 24**

The provisions of Article 14 of the Convention on settlement of disputes shall apply *mutatis mutandis* to this Agreement.

**Article 25**

1. Each Party shall have one vote, except as provided for in paragraph 2 of this Article.

2. Regional economic integration organizations, in matters within their competence, shall exercise their right to vote with a number of votes equal to the number of their member States that are Parties to this Agreement. Such an organization shall not exercise its right to vote if any of its member States exercises its right, and vice versa.

**Article 26**

The Secretary-General of the United Nations shall be the Depositary of this Agreement.

**Article 27**

No reservations may be made to this Agreement.

## Article 28

1. At any time after three years from the date on which this Agreement has entered into force for a Party, that Party may withdraw from this Agreement by giving written notification to the Depositary.

2. Any such withdrawal shall take effect upon expiry of one year from the date of receipt by the Depositary of the notification of withdrawal, or on such later date as may be specified in the notification of withdrawal.

3. Any Party that withdraws from the Convention shall be considered as also having withdrawn from this Agreement.

## Article 29

The original of this Agreement, of which the Arabic, Chinese, English, French, Russian and Spanish texts are equally authentic, shall be deposited with the Secretary-General of the United Nations.

DONE at Paris this twelfth day of December two thousand and fifteen.

IN WITNESS WHEREOF, the undersigned, being duly authorized to that effect, have signed this Agreement.

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៨៤០ សជណ.ករបក

**សូមគោរពជូន**

**សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**

**កម្មវត្ថុ:** សំណើសុំពិនិត្យ និងអនុម័តនូវសេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្ដីពីការប្រែប្រួលអាកាសធាតុ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមផ្ញើជូនសម្ដេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា នូវសេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្ដីពីការប្រែប្រួលអាកាសធាតុ ដែលទទួលបានការសម្រេចយល់ព្រមពីគណៈរដ្ឋមន្ត្រីរួចហើយក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦ ដើម្បីបំពេញបែបបទ និងនីតិវិធី ដូចមានអត្ថន័យក្នុងសេចក្ដីថ្លែងហេតុ ដែលភ្ជាប់មកជាមួយនេះ។

អាស្រ័យហេតុនេះ សូមសម្ដេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា មេត្តាដាក់សេចក្ដីព្រាងច្បាប់នេះ ជូនរដ្ឋសភាពិនិត្យ និងអនុម័ត ដោយអនុគ្រោះ។

សូមសម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

# សេចក្តីព្រាង

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ

**មាត្រា១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០១៦
នាសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី៥។
រាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ២០១៦

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខៈ ១១៩៤ សណ.ប.ស្ត

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុៈ** សំណើសុំពិនិត្យ និងស្នើទៅស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីផ្តល់សច្ចាប័នកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ

**យោង** ៖ - លិខិតលេខ ១៣១ ស.ជ.ណ. ក.ស. ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ របស់ឯកឧត្តម បាន គីមូន អគ្គលេខាធិការ អង្គការសហប្រជាជាតិ
- លិខិតលេខ ៥៣៨១ អជ.កបទ.សអ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា កិច្ចព្រមព្រៀងទីក្រុងប៉ារីស (Paris Agreement) ស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានអនុម័តនៅក្នុងសន្និសីទបណ្តាភាគីលើកទី២១ (CoP21) នៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ដែលបានប្រព្រឹត្តទៅកាលពីខែធ្នូ ឆ្នាំ២០១៥ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុជាមួយបណ្តាប្រទេសចំនួន១៧៥ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ នៅក្រុងញូវយ៉ក។ មកទល់បច្ចុប្បន្នមានប្រទេសចំនួន១៧៧ បានចុះហត្ថលេខា ហើយប្រទេសចំនួន១៩ បានដាក់លិខិតូបករណ៍ផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះជូនអង្គការសហប្រជាជាតិរួចហើយ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសអាចចូលជាធរមានបានលុះត្រាតែមានប្រទេសជាភាគីយ៉ាងតិច៥៥ ស្មើនឹង៥៥% នៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សាកល ដាក់លិខិតូបករណ៍ផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះ។

ការផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀងនេះ នឹងផ្តល់កាលានុវត្តភាពដល់កម្ពុជា ក្នុងការពង្រឹងសមត្ថភាពជាតិសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងផ្តល់អត្ថប្រយោជន៍នានាសម្រាប់ប្រទេសកម្ពុជា ដូចជាការទទួលបានហិរញ្ញវត្ថុបន្ថែមសម្រាប់សកម្មភាពបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការផ្ទេរបច្ចេកវិទ្យា និងការបង្កើនសមត្ថភាព។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចស្នើទៅស្ថាប័ននីតិប្បញ្ញត្តិ ដើម្បីផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ដោយសេចក្តីអនុគ្រោះបំផុត។

សូមគោរពជូនភ្ជាប់មកជាមួយនូវឯកសារដើមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ជាភាសាអង់គ្លេស និងបកប្រែជាភាសាខ្មែរ ចំនួន ០២ច្បាប់ ឯកសារសង្ខេបនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងការវិភាគអត្ថប្រយោជន៍ ដែលទទួលបានពីកិច្ចព្រមព្រៀងនេះ ចំនួន ០១ច្បាប់។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**សាយ សំអាល់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ : ១១១៤ សាង.ណប.ស្ក

# សេចក្តីថ្លែងហេតុ
## ស្តីពី
## ការស្នើសុំផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ

ជាបឋមខ្ញុំបាទ

- *សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *សូមគោរព សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ជាទីគោរព!*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ជាទីគោរពរាប់អាន!*

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុញ្ញាតឱ្យក្រសួងបរិស្ថានដាក់សំណើសុំផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ ទៅក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃនេះ ដើម្បីសុំការពិនិត្យ និងអនុម័តដ៏ខ្ពង់ខ្ពស់។

ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងអង្គប្រជុំទាំងមូលមេត្តាជ្រាបថា ក្នុងនាមជាស្ថាប័នបង្គោលនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ក្រសួងបរិស្ថាន បានរៀបចំឯកសារសម្រាប់ព្រះរាជាណាចក្រកម្ពុជាផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមនីតិវិធីច្បាប់ដែលមានជាធរមាន។

ខ្ញុំបាទសុំការអនុញ្ញាតពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីជម្រាបជូនអង្គប្រជុំអំពីប្រវត្តិសង្ខេប និងអត្ថប្រយោជន៍ នៃកិច្ចព្រមព្រៀងស្តីពីការប្រែប្រួលអាកាសធាតុ ដែលមានខ្លឹមសារដូចខាងក្រោមៈ

